**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ:០០៣............សរាចរ.....កសក

# សេចក្តីណែនាំ
## ស្តីពី
## វិធានការការពារនិងទប់ស្កាត់ភ្លើងឆេះព្រៃ

ជារៀងរាល់ឆ្នាំ ធាតុអាកាសទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជាចាប់ផ្តើមផ្លាស់ប្តូរពីរដូវវស្សា ចូលដល់រដូវលំហើយ ហើយបន្តចូលរដូវប្រាំងដែលធាតុអាកាសមានសភាពក្តៅហែង ស្ងួតខ្លាំង ជាលក្ខខណ្ឌងាយបង្កនូវភ្លើងឆេះព្រៃ។ ក្រៅពីបាតុភូតធម្មជាតិដែលអាចបង្កឱ្យមានភ្លើងឆេះព្រៃ ប្រការដែលគួរឱ្យព្រួយបារម្ភបំផុតនោះ គឺភ្លើងឆេះព្រៃដែលបង្កឡើងដោយសារសកម្មភាពរបស់មនុស្សផ្ទាល់។ កត្តាចម្បងដែលបង្កឱ្យមានភ្លើងឆេះព្រៃញឹកញាប់បំផុតនារដូវប្រាំង តាមរយៈសកម្មភាពមានជាអាទិ៍: ការកាប់ឆ្ការដុតរានព្រៃដើម្បីអភិវឌ្ឍន៍ដំណាំកសិកម្ម ដំណាំកសិឧស្សាហកម្ម ការធ្វើកសិកម្មពនេចរ ការតាំងទីលំនៅដ្ឋានថ្មី ការដុតព្រៃដើម្បីចាប់សត្វ ការបន្សល់ដើមភ្លើងនៅក្នុងព្រៃតាមរយៈការធ្វេសប្រហែសរបស់មនុស្ស។ល។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកត់សំគាល់ឃើញថា ភ្លើងឆេះព្រៃជារៀងរាល់ឆ្នាំបានបង្កឱ្យមានបញ្ហាដ៏ធ្ងន់ធ្ងរដល់ការបាត់បង់ធនធានព្រៃឈើនិងព្រៃលិចទឹក ហើយនិងបានបង្កនូវវិនាសកម្មនិងការខាតបង់យ៉ាងធ្ងន់ធ្ងរដល់សង្គមសេដ្ឋកិច្ចជនបទ សេដ្ឋកិច្ចជាតិ ធនធានធម្មជាតិ និងបរិស្ថាន។

ដោយសង្កេតឃើញបញ្ហាប្រឈមទាំងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់មន្ត្រីរដ្ឋបាលព្រៃឈើនិងរដ្ឋបាលជលផល ដើម្បីអនុវត្តវិធានការដូចខាងក្រោម៖

១-ទប់ស្កាត់ការប្រើប្រាស់ភ្លើងជាមធ្យោបាយដើម្បីយកឃ្មុំ ការដុតស្វាក់ចាប់សត្វព្រៃ និងការដុតវាលស្មៅក្នុងព្រៃ ដើម្បីយកល្បាស់ធ្វើចំណីសត្វពាហនៈ។

២-ទប់ស្កាត់ការកាប់ឆ្ការ គាស់រាន ឈូសឆាយ ដុតព្រៃឈើនិងព្រៃលិចទឹក ដើម្បីពង្រីកផ្ទៃដីដំណាំកសិកម្មឬក្នុងគោលបំណងផ្សេងទៀតដែលជាសកម្មភាពល្មើសច្បាប់និងនាំមកនូវភ្លើងឆេះព្រៃឈើ និងព្រៃលិចទឹក។

៣-ក្នុងករណីចាំបាច់ដែលត្រូវប្រើភ្លើងជាមធ្យាបាយក្នុងការដុតកាកសំណល់ឈើព្រៃ ក្រោមគោលបំណងអភិវឌ្ឍន៍ដំណាំកសិកម្ម ដំណាំកសិឧស្សាហកម្ម និងសកម្មភាពស្របច្បាប់ផ្សេងទៀត ត្រូវជូនដំណឹងដល់សង្កាត់រដ្ឋបាលព្រៃឈើឬសង្កាត់រដ្ឋបាលជលផលសាមី ដើម្បីណែនាំអនុវត្តវិធានការបច្ចេកទេសសមស្របដែលអាចធានាសុវត្ថិភាពចំពោះភ្លើងព្រៃ។

៤-ការរុករកផល អនុផលព្រៃឈើជាប្រពៃណីនិងសកម្មភាពផ្សេងទៀតដែលចាំបាច់ត្រូវប្រើភ្លើងជាមធ្យោបាយ(ដុតរណ្តៅជ័រ) ត្រូវណែនាំពន្លត់ភ្លើងឱ្យអស់ជាចាំបាច់មុនពេលចាកចេញពីដើមឈើច្បោះជ័រឬទីតាំងដែលប្រើភ្លើងនោះ។

៥-ក្នុងករណីកើតមានភ្លើងឆេះព្រៃ ត្រូវប្រញាប់ចាត់វិធានការទប់ស្កាត់ជាបន្ទាន់តាមរយៈការប្រកាសអាសន្ន និងស្នើអភិបាលនៃគណៈអភិបាលខេត្ត ជាប្រធានអនុគណៈកម្មាធិការខេត្តដើម្បីទប់ស្កាត់លុបបំបាត់

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon , Phnom Penh, Cambodia.
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

និងបង្ក្រាបការកាប់រានដុតឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើធ្វើជាកម្មសិទ្ធិទទួលដឹកនាំបញ្ជាផ្ទាល់ក្នុងការប្រើកម្លាំងសរុបរួមមាន ប្រជាពលរដ្ឋ សហគមន៍ សិស្សានុសិស្ស ព្រះសង្ឃ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ។ល។ ដែលឈរជើងនៅក្នុងមូលដ្ឋាននោះ ដើម្បីរួមគ្នាទប់ស្កាត់និងពន្លត់ភ្លើងព្រៃឱ្យមានប្រសិទ្ធភាព។

៦-ក្រោមការដឹកនាំរបស់ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត រដ្ឋបាលព្រៃឈើនិងរដ្ឋបាលជលផល ត្រូវចាត់វិធានការតាមផ្លូវច្បាប់ចំពោះជនណាដែលបានកាប់រុករាន ដុតព្រៃ និងកាន់កាប់ដីព្រៃឈើដែលឆេះហើយដោយអនាធិបតេយ្យដែលផ្ទុយនឹងច្បាប់ និងប៉ះពាល់ដល់នយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី និងបទបញ្ជានានារបស់រាជរដ្ឋាភិបាល។

៧-ត្រូវសហការជាមួយអាជ្ញាធរដែនដីក្នុងការហាមឃាត់ចូលប្រើប្រាស់ដីព្រៃឈើ និងព្រៃលិចទឹកដែលឆេះរួច ដើម្បីទុកលទ្ធភាពឱ្យរុក្ខជាតិដុះឡើងវិញតាមលក្ខណៈធម្មជាតិ។

អនុលោមតាមច្បាប់ស្តីពីព្រៃឈើនិងច្បាប់ស្តីពីជលផល ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់ ត្រូវមានករណីយកិច្ចទទួលខុសត្រូវថែរក្សា ការពារព្រៃឈើ បង្ការនិងប្រយុទ្ធនឹងភ្លើងឆេះព្រៃ ចូលរួមថែរក្សាជម្រកមច្ឆជាតិ ការពារបង្ការនិងប្រយុទ្ធនឹងភ្លើងឆេះព្រៃលិចទឹក នៅតាមមូលដ្ឋានរៀងៗខ្លួន។ ជនណាដែលបានប្រព្រឹត្តឬបង្កឱ្យមានភ្លើងឆេះព្រៃ ឬភ្លើងឆេះព្រៃលិចទឹកដោយចេតនាត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី១ឬបទល្មើសជលផលថ្នាក់ទី១ ដែលត្រូវជាប់ពន្ធនាគារពី០៥ឆ្នាំទៅ១០ឆ្នាំឬពី០៣ឆ្នាំទៅ០៥ឆ្នាំ។

ទទួលបានសេចក្តីណែនាំនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានជំនឿនិងទំនុកចិត្តចំពោះគ្រប់ស្ថាប័នមានសមត្ថកិច្ច រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ សហគមន៍ សិស្សានុសិស្ស ព្រះសង្ឃ និងប្រជាពលរដ្ឋទាំងអស់បានយល់ច្បាស់ពីករណីយកិច្ចក្នុងការការពារ ទប់ស្កាត់និងប្រយុទ្ធនឹងភ្លើងឆេះព្រៃ ដោយរួមសហការយ៉ាងជិតស្និទ្ធជាមួយសមត្ថកិច្ចរដ្ឋបាលព្រៃឈើនិងរដ្ឋបាលជលផលក្នុងមូលដ្ឋានរៀងៗខ្លួន អនុវត្តតាមសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

បណ្ឌិត អ៊ុក រ៉ាប៊ុន

**កន្លែងទទួល**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងមហាផ្ទៃ
- -ក្រសួងការពារជាតិ
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងធនធានទឹក និងឧតុនិយម
- -ក្រសួងយុត្តិធម៌
- -ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- -ខុទ្ទកាល័យសម្តេចអគ្គសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -សាលារាជធានី ខេត្ត
- -អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- -មន្ទីរកសិកម្មរាជធានី ខេត្ត
- -ឯកសារ កាលប្បវត្តិ